# ព្រះរាជក្រឹត្យ

នស/រកត/០៦១៧/៥៧២

## ស្តីពី

## ការកែសម្រួលមាត្រា៧ មាត្រា៩ និងមាត្រា៣២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១៦/១៨៤ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៤ និងមាត្រា២២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសបង្គាប់

**មាត្រា មួយ.-**

មាត្រា៧ មាត្រា៩ និងមាត្រា៣២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា ត្រូវបានកែសម្រួលនិងបំពេញបន្ថែមដូចតទៅ៖

**មាត្រា ៧ថ្មី.-**

**មហាសន្និបាត**

- មហាសន្និបាទ **គ.ទិ.ក.** ប្រព្រឹត្តិទៅ ០៥(ប្រាំ)ឆ្នាំម្តង ដើម្បីរៀបចំបោះឆ្នោតជ្រើសរើសអគ្គលេខាធិការ និងអគ្គលេខាធិការរង

- មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តិទៅបាន តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា **គ.ទិ.ក.** ឬតាមការស្នើសុំពីវិស្វករចុះបញ្ជីយ៉ាងតិចចំនួន ៣០(សាមសិប)ភាគរយ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំ ដោយមានភ្ជាប់របៀបវារៈមកជាមួយផង។

**សន្និបាត**

- សន្និបាតប្រចាំឆ្នាំ **គ.ទិ.ក.** ត្រូវប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានក្រុមប្រឹក្សា **គ.ទិ.ក.**។

**មាត្រា ៩ថ្មី.-**

ក្រុមប្រឹក្សា **គ.ទិ.ក.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិ ដែលមានបទពិសោធខាងវិស័យវិស្វកម្ម | អនុប្រធាន |
| - តំណាងក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្ម | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល | សមាជិក |
| - តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| - អគ្គលេខាធិការ **គ.ទិ.ក.** | សមាជិកអចិន្ត្រៃយ៍ |

សមាសភាពក្រុមប្រឹក្សា **គ.ទិ.ក.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា ៣២ថ្មី.-**

ប្រភពធនធានរបស់ **គ.ទិ.ក.** សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ភាគទានដែលបានពីសមាជិក **គ.ទិ.ក.**
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណងផ្សេងៗ។

**គ.ទិ.ក.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា បី.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧

នស/រកត/០៦១៧/៥៧៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា**

**ហត្ថលេខា**

**អ៊ិត សំហេង**

លេខ: ៥៣៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**